# ច្បាប់ធម្មនុញ្ញបន្ថែម
# សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

## ព្រះរាជក្រម

នស/រកម/០៧០៤/០០១

### យើង
### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

## ប្រកាសឲ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានឲ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែក



មាតិកា

កុដា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី១ ហើយដែលមានសេចក្តី ទាំងស្រុងដូចតទៅ៖

## ច្បាប់ធម្មនុញ្ញបន្ថែម
## សំដៅ
## ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

### មាត្រា ១._

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។

### មាត្រា ២._

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និងក្រោយពេលសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័តអត្ថបទដែលមានចារិកជារដ្ឋធម្មនុញ្ញ ឬច្បាប់ ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សម្រាប់អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសឲ្យចូលជាធរមាន។

### មាត្រា ៣._

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨៣ និង ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការ ក្នុងពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

**មាត្រា ៤.–**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅៈ

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយ ដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។

- តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់ នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

- ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។

**មាត្រា ៥.–**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីបានឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយវិធីលើកដៃ។

## មាត្រា ៦.‒ ថ្មី[40]

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត។

## មាត្រា ៧.‒

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និងយកមកអនុវត្ត ចាប់តាំងពីដើមនីតិកាលបច្ចុប្បន្ននេះទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ពរល.០៤.០៧.១១៧

**ប្រមុខរដ្ឋស្ដីទី**
**មហាក្សត្រលេខានិងព្រះរាជលញ្ឆករ**
**ញឹក ប៊ុនឆៃ**

[40] ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី(មួយ) មាត្រា១១៤ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ២០០៦។

# គណៈកម្មាធិការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ
# បានអនុម័តដោយសភាធម្មនុញ្ញ នាសម័យប្រជុំពេញអង្គលើកទី ១
# ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ១៩៩៣

១- ឯកឧត្តមសម្ដេចប្រធានសភាធម្មនុញ្ញ ឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ
"ករណីសម្ដេចប្រធានអវត្តមាន" ជាប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម | ចែម ស្ងួន | ជាអនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត | តាវ សេងហួរ | ជាអ្នករាយការណ៍ |
| ៤- ឯកឧត្តម | កាន់ ម៉ន | ជាសមាជិក |
| ៥- ឯកឧត្តម | គាត ឈន់ | ជាសមាជិក |
| ៦- ឯកឧត្តម | ឈួរ លាងហួត | ជាសមាជិក |
| ៧- ឯកឧត្តម | ថោ ប៉េងលាត | ជាសមាជិក |
| ៨- ឯកឧត្តម | សម វង្ស៊ី | ជាសមាជិក |
| ៩- អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ សិរីរ័ត្ន | ជាសមាជិក |
| ១០- ឯកឧត្តម | សឺន ស៊ូប៊ែរ្ត | ជាសមាជិក |
| ១១- ឯកឧត្តម | សោម ចាន់បុត្រ | ជាសមាជិក |
| ១២- ឯកឧត្តម | អ៊ុន នឹង | ជាសមាជិក |
| ១៣- ឯកឧត្តម | ឡូយ ស៊ីមឈាង | ជាសមាជិក |
| ១៤- ឯកឧត្តម | ជាម យៀប | ជាសមាជិកបំរុង |
| ១៥- ឯកឧត្តម | ប៉ុល ហំម | ជាសមាជិកបំរុង |
| ១៦- ឯកឧត្តម | ពូ សុធីរៈ | ជាសមាជិកបំរុង |
| ១៧- ឯកឧត្តម | សរ សាអាត | ជាសមាជិកបំរុង |
| ១៨- ឯកឧត្តម | អ៊ឹង គៀត | ជាសមាជិកបំរុង |
| ១៩- ឯកឧត្តម | អ៊ុក រ៉ាប៊ុន | ជាសមាជិកបំរុង |
| ២០- ឯកឧត្តម | អ៊ុង ផន | ជាសមាជិកបំរុង |



មាតិកា

| | | |
|---|---|---|
| ២១- ឯកឧត្តម | ឯក សំអុល | ជាសមាជិកបំរុង |
| ២២- ឯកឧត្តម | សាយ បូរី | ជាអ្នកជំនាញការ |
| ២៣- ឯកឧត្តម | ចាន់ សុខ | ជាអ្នកជំនាញការ |
| ២៤- ឯកឧត្តម | ឈន អៀម | ជាអ្នកជំនាញការ |
| ២៥- ឯកឧត្តម | ហេង វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦- ឯកឧត្តម | ខៀវ រ៉ាដា | ជាអ្នកជំនាញការ |

កំណត់សំគាល់៖ យោងជំពូកទី ៧ ប្រការ ១៨ ស្តីពីគណៈកម្មការនិងប្រធានគណៈកម្មការសភាជម្មនុញ្ញ។

# ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
# និងច្បាប់ធម្មនុញ្ញបន្ថែម

1. ច្បាប់ធម្មនុញ្ញស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤
2. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩
3. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០១
4. ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤
5. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥
6. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី(មួយ) មាត្រា១១៤ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ២០០៦
7. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

8. ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៤

9. ច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និង មាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៨។

# កំណត់សម្គាល់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។

មកដល់ចុងឆ្នាំ ២០១៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្មចំនួន ៨ លើក និងបន្ថែមចំនួន ១ លើក ដូចខាងក្រោម៖

១. ច្បាប់ស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញនីតិកាលទី ១។ ការកែប្រែនេះ ដើម្បីផ្តល់សិទ្ធិដល់ប្រមុខរដ្ឋស្តីទីចុះហត្ថលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ នៅពេលព្រះមហាក្សត្រអវត្តមាន ដោយព្រះរាជសារប្រគល់សិទ្ធិ។

២. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី២។ វិសោធនកម្មនេះ ដើម្បីបង្កើតឲ្យមានស្ថាប័នព្រឹទ្ធសភា។

៣. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ចែងអំពី "ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ" និងកែតម្រូវកំហុសបច្ចេកទេសនូវមាត្រា ១៩ ថ្មី ត្រង់លេខមាត្រាយោងពីមាត្រា ១០០ ចាស់ ទៅមាត្រា ១៩៩ ថ្មី។

៤. ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៤ នាសម័យ

ប្រជុំរដ្ឋសភាលើកទី ១ នីតិកាលទី ៣ ។ ច្បាប់ធម្មនុញ្ញបន្ថែមនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលិទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។

៥. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ បានកែប្រែកូរ៉ុមនៃការប្រជុំរដ្ឋសភា៖

- កូរ៉ុមប្រាំពីរភាគដប់សម្រាប់ការអនុម័តយកមតិភាគច្រើន ពីរភាគបី ឬយកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។
- កូរ៉ុមប្រាំមួយភាគដប់សម្រាប់ការអនុម័តយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

៦. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ២ ខែមីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣។ ច្បាប់ធម្មនុញ្ញនេះសំដៅកែសម្រួលសម្លេងបោះឆ្នោតពីសម្លេងពីរភាគបីមកជាមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមប្រជុំដើម្បី៖

- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកគណៈកម្មការនានានៃរដ្ឋសភា
- បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល និងអនុម័តញត្តិបន្ទោសទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល
- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកគណៈកម្មការនានានៃព្រឹទ្ធសភា
- អនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានិងព្រឹទ្ធសភា។

៧. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ ថ្មី និងមាត្រា ១៤៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ចែងអំពីការបែងចែកទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

៨. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និងមាត្រាទាំងឡាយពីជំពូកទី ១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១៤ ដោយបញ្ញត្តិអំពីអង្គការរៀបចំការបោះឆ្នោតជាស្ថាប័នធម្មនុញ្ញ។

៩. ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៨ បញ្ញត្តិ៖

- ប្តូរពី បន្ថយសិទ្ធិបោះឆ្នោត មកជា ដកសិទ្ធិបោះឆ្នោត
- ហាមគណបក្សនយោបាយ មិនឲ្យធ្វើសកម្មភាពនាំឲ្យប៉ះពាល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋខ្មែរ
- ហាមប្រជាពលរដ្ឋខ្មែរគ្រប់រូប មិនឲ្យធ្វើសកម្មភាពនាំឲ្យប៉ះពាល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋខ្មែរ
- ប្រឆាំងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា
- ដកមុខតំណែងរដ្ឋលេខាធិការចេញពីគណៈរដ្ឋមន្ត្រី។

រដ្ឋធម្មនុញ្ញបច្ចុប្បន្ន មាន ១៦០ មាត្រា ដែលចែកចេញជា ១៧ ជំពូក មានបុព្វកថា អំពីអធិបតេយ្យ អំពីព្រះមហាក្សត្រ អំពីសិទ្ធិនិងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ អំពីរបបនយោបាយ អំពីសេដ្ឋកិច្ច អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច អំពីរដ្ឋសភា អំពីព្រឹទ្ធសភា អំពីសមាជរដ្ឋសភានិងព្រឹទ្ធសភា អំពីរាជរដ្ឋាភិបាល អំពីអំណាចតុលាការ អំពីក្រុមប្រឹក្សាធម្មនុញ្ញ អំពីការគ្រប់គ្រងរដ្ឋបាល អំពីសមាជជាតិ អំពីអង្គការរៀបចំការបោះ

ឆ្នោត អំពីអានុភាពការសើរើនិងវិសោធនកម្មរដ្ឋធម្មនុញ្ញ អំពីអន្តរប្បញ្ញត្តិ ភ្ជាប់ដោយឧបសម្ព័ន្ធចំនួន ៧។